# គំនិត
# បង្កើតមូលនិធិ

ប្រទេសកម្ពុជានាពេលបច្ចុប្បន្នមានសិល្បករ និងប្រតិបត្តិករសិល្បៈវប្បធម៌ជាច្រើនដែលមានសក្តានុពល និងលេចធ្លោ ទៅលើគំនិតច្នៃប្រតិដ្ឋក្នុងការបង្កើតស្នាដៃថ្មីៗ ដែលមានគុណតម្លៃ និងមានភាពជាអ្នកដឹកនាំក្នុងគំនិតផ្តួចផ្តើមផ្សេងៗរបស់ពួកគេ។ អ្នកទាំងអស់នោះត្រូវការការគាំទ្រដើម្បីឆ្លុះបញ្ចាំង និងអភិវឌ្ឍខ្លួនបន្ថែមទាំងជំនាញសិល្បៈ និងមិនមែនសិល្បៈ។

ដោយមើលឃើញភាពចាំបាច់ទាំងអស់នេះក្នុងវិស័យសិល្បៈវប្បធម៌ជាពិសេសក្នុងបរិបទប្រទេសកម្ពុជានាពេលបច្ចុប្បន្ន យើងបានបង្កើតជាមូលនិធិ និងឱកាសផ្សេងៗជាច្រើន ដើម្បីជំរុញដល់សិល្បករ និងប្រតិបត្តិករក្នុងវិស័យសិល្បៈវប្បមឺទាំងអស់នោះឱ្យឈានទៅដល់គោលដៅ និងកសាងប្រពន្ធ័អេកូសិល្បៈដែលមានភាពរឹងមាំហើយផ្សារភ្ជាប់ទៅនឹងការអភិវឌ្ឍសង្គមកម្ពុជា។



“មានហេតុផលជាច្រើន ដែលអ្នកគួរដាក់ពាក្យស្នើសុំមូលនិធិទាំងនេះ មិនត្រឹមតែទទួលបានការគាំទ្រថវិកាប៉ុណ្ណោះទេ វាថែមទាំងផ្តល់ឱកាសដល់សិល្បករក្នុងការសរសេរនិងរៀបចំសំណើរស្នើសុំ ដែលទាមទារឲ្យយើងខិតខំបញ្ចេញនូវគំនិតដាក់លាក់ពីចំណុចមួយទៅចំណុចមួយ នៅពេលដែលយើងមានទំនុកចិត្តបង្ហាញពីការប្រតិបត្តិការងាររបស់យើង ហើយយើងនឹងអាចឆ្លុះបញ្ចាំងបានកាន់តែច្បាស់ពីអ្វីដែលយើងបានធ្វើ។



**ពេជ្រ សុភាព**
សិល្បករចក្ខុទស្សន៍ និងទីប្រឹក្សាកម្មវិធី

“មូលនិធិដាំដុះខ្នាតតូចសម្រាប់គម្រោងជាកត្តាជំរុញមួយដែលបានផ្តល់ការឧបត្ថម្ភគាំទ្រ និងជួយសម្រួលយ៉ាងខ្លាំងដល់ដំណើរការការងារស្រាវជ្រាវរបស់ខ្ញុំពីឧបករណ៍ភ្លេងជនជាតិដើមភាគតិច ឱ្យខ្ញុំមានឱកាសកត់ត្រា និងចងក្រងសម្រាប់យុវជនជំនាន់ក្រោយ។



**ទីវ ស៊ីម**
អ្នកទទួលបានមូលនិធិដាំដុះសម្រាប់គម្រោង

សិល្បៈខ្មែរអមតៈ

ទំនាក់ទំនងព័ត៌មានអំពីមូលនិធិ៖

តាមដានព័ត៌មាន៖

# ហេតុអ្វី
## បានជាយើងបង្កើតឱកាស
## ទាំងអស់នេះឡើង?



សិល្បៈខ្មែរអមតៈ



© Photo credit: CHHEN Kimhong

# ព័ត៌មាន
# អំពីមូលនិធិនីមួយៗ

## មូលនិធិចល័ត

មូលនិធិនេះបើកពេញមួយឆ្នាំដែលផ្តល់ឱកាសឱ្យសិល្បករ និងអ្នកធ្វើការងារក្នុងវិស័យសិល្បៈវប្បធម៌ ដើម្បីស្នើសុំមូលនិធិនេះទៅចូលរួមព្រឹត្តិការណ៍សិល្បៈផ្សេងៗ នៅក្នុងតំបន់អាស៊ី។

## អាហារូបករណ៍សិល្បៈអមតៈ អាន ចន ផន

គាំទ្រដល់សិល្បករ សិស្ស និស្សិត គ្រូ និងអ្នកបម្រើការក្នុងវិស័យសិល្បៈវប្បធម៌ដែលមានទេពកោសល្យដើម្បីបន្តអាជីពការងាររបស់ពួកគេក្នុងវិស័យសិល្បៈទាំងទៅលើជំនាញសិល្បៈ និងជំនាញមិនមែនសិល្បៈ។

## មូលនិធិដំឡើងស្នាដៃថ្មី

គាំទ្រដល់សិល្បករដែលមានបំណងបង្កើតស្នាដៃថ្មី ឬត្រូវការការអភិវឌ្ឍបន្ថែមទៅលើស្នាដៃថ្មីដែលមានស្រាប់។ មូលនិធិនេះផ្តោតសំខាន់លើដំណើរការបង្កើតស្នាដៃសម្រាប់សិល្បករក្នុងការដកពិសោធន៍គំនិតច្នៃប្រតិដ្ឋ និងប្រាប់ពីរឿងរ៉ាវរបស់ពួកគេក្នុងបរិបទប្រទេសកម្ពុជានាពេលបច្ចុប្បន្ន។

## មូលនិធិដាំដុះ

គាំទ្រលើគម្រោងសិល្បៈច្នៃប្រតិដ្ឋ គម្រោងសិល្បៈសហគមន៍ (ថ្នាក់បង្រៀនសិល្បៈ ឬសកម្មភាពសិល្បៈផ្សេងៗក្នុងសហគមន៍) គម្រោងស្រាវជ្រាវពីសិល្បៈ និងវប្បធម៌នៅកម្ពុជា (ការស្រាវជ្រាវលើប្រវត្តិសិល្បៈ ការស្រាវជ្រាវនរវិទ្យាផ្នែកវប្បធម៌ គោលនយោបាយវប្បធម៌ ។ល។)

## មូលនិធិជឿនលឿន

គាំទ្រលើការអភិវឌ្ឍដល់សិល្បករឯករាជ្យ និងអ្នកជំនាញផ្នែកសិល្បៈវប្បធម៌ដែលមានភាពច្នៃប្រតិដ្ឋ ចង់សាកល្បងហានិភ័យថ្មី និងធ្វើការក្នុងវិធីសាស្ត្រថ្មី ដែលអាចឈានទៅចាប់យកទស្សនិកជនថ្មីផងដែរ។ មូលនិធិនេះផ្តោតការយកចិត្តទុកដាក់ស៊ីជម្រៅក្នុងការអភិវឌ្ឍគម្រោងច្នៃប្រតិដ្ឋនិងជួយពង្រឹងសមត្ថភាពរបស់បេក្ខជនមួយកម្រិតទៀត។



អង្គការសិល្បៈខ្មែរអមតៈ លើកទឹកចិត្តដល់សហគមន៍ដែលមានសំឡេងតិច រួមមាន សហគមន៍ជនជាតិដើម, អ្នកមានពិការភាព, ស្ត្រី និងអ្នកដែលមិនធ្លាប់បានទទួលឱកាសទាំងនេះពីមុនមកឱ្យដាក់ពាក្យស្នើសុំ។

យើងផ្តល់ឱកាស ៥០ ភាគរយ សម្រាប់ស្ត្រី ២៥ ភាគរយ សម្រាប់អ្នកដែលមិនធ្លាប់ទទួលបានឱកាសពីអង្គការសិល្បៈខ្មែរអមតៈ និង ២៥ ភាគរយទៀត សម្រាប់អ្នកដែលធ្លាប់ទទួលបានមូលនិធិពីអង្គការសិល្បៈខ្មែរអមតៈ។

## តារាងពេលវេលាបើកប្រកាសមូលនិធិ

<table>
<tr><th>ខែ ១</th><th>ខែ ២</th><th>ខែ ៣</th><th>ខែ ៤</th><th>ខែ ៥</th><th>ខែ ៦</th><th>ខែ ៧</th><th>ខែ ៨</th><th>ខែ ៩</th><th>ខែ ១០</th><th>ខែ ១១</th><th>ខែ ១២</th></tr>
<tr><td colspan="12">មូលនិធិចល័ត</td></tr>
<tr><td></td><td></td><td colspan="3">អាហារូបករណ៍សិល្បៈ អាន ចន ផន</td><td></td><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td></td><td></td><td></td><td></td><td></td><td></td><td colspan="2">មូលដំឡើងស្នាដៃថ្មី</td><td></td><td></td><td></td><td></td></tr>
<tr><td></td><td></td><td></td><td></td><td></td><td></td><td></td><td colspan="3">មូលនិធិដាំដុះ</td><td></td><td></td></tr>
<tr><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td colspan="2">មូលនិធិជឿនលឿន</td><td></td><td></td></tr>
</table>